**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៩០៦៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២

**គោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ លោក លោកស្រី**
**ជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាព ក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្នាក់កណ្តាលនិងតាមរាជធានី ខេត្ត**

**កម្មវត្ថុ** ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៣ ។

**យោង**
- ព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រមលេខ នស /រកម/ ១២១១/០១៩ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៤០ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- អនុក្រឹត្យលេខ ១៣៨ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ៤០៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារក្រមសីលធមិសម្រាប់សវនករផ្ទៃក្នុង និងស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង
- ប្រកាសលេខ ១១០៩ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង
- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការពង្រឹង

មុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ

- លិខិតលេខ ១៦៣៨ សហវ.សជក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ស្តីពីផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០១១-២០១៣
- សារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- ផ្អែកតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រតិភូ លោកជំទាវ ឯកឧត្តម លោកស្រី លោកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពនានាក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជ្រាបថា ដើម្បីបន្តរក្សានិរន្តរភាពជោគជ័យនៃកំណែទម្រង់របស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់វិស័យហិរញ្ញវត្ថុសាធារណៈនិយាយជារួម និងនិយាយដោយឡែក ការកសាងលក្ខណៈសម្បត្តិសម្រាប់បោះជំហានចូលដំណាក់កាលទី ៣ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំនាយកដ្ឋានសវនកម្មផ្ទៃក្នុង ឱ្យរៀបចំផែនការសវនកម្មប្រចាំឆ្នាំ ២០១៣ អនុលោមតាមផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំ ២០១១-២០១៣ ដោយកែតម្រូវសំដៅធានាភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យថ្មី ដែលជាសមិទ្ធកម្មនៃវឌ្ឍនភាពថ្មីៗ ក្នុងការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ នេះ ពិសេសកើតចេញពីសកម្មភាពនៃយុទ្ធសាស្ត្រ ៣+២ គឺការពង្រឹងបន្ទាត់គណនេយ្យភាព ស្តង់ដារការអនុវត្តថវិកា សមត្ថភាព និងការត្រៀមដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យាលើមូលដ្ឋានរតនាគារ (FMIS Treasury Centric Module) រួមទាំងផ្តល់ការគាំទ្រដើម្បីសម្រេចគោលដៅបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ផងដែរ។

ការរៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៣ នេះក៏ត្រូវបានណែនាំឲ្យធានាបាននូវភាពជាក់ស្តែង និងអាចអនុវត្តបានផងដែរ ដោយតម្រូវឲ្យរក្សានូវអភិក្រម និងនីតិវិធីរៀបចំតាមស្តង់ដារសវនកម្មល្អប្រសើរ ព្រមទាំងយកចិត្តទុកដាក់លើសមត្ថភាព ធនធានមនុស្ស ពេលវេលា និងលទ្ធភាពរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងផ្ទាល់ ។

ជាលទ្ធផលផែនការសវនកម្មប្រចាំឆ្នាំ ២០១៣ នេះបានគ្របដណ្តប់ទៅលើអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពសំខាន់ៗថ្នាក់កណ្តាលចំនួន ១២ ជាអាទិ៍មានៈ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គាធិការដ្ឋាន នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញ

វត្ថុសាធារណៈ ព្រមទាំងអង្គភាពតាមរាជធានី-ខេត្ត (សូមពិនិត្យតារាងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៣ ដូចជូនភ្ជាប់) ។

សវនកម្មលើអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពនៅថ្នាក់កណ្តាល និងតាមរាជធានី-ខេត្ត មានគោលបំណងជួយឲ្យថ្នាក់ដឹកនាំគ្រប់គ្រងបាននូវហានិភ័យ ធានាបានប្រសិទ្ធភាពប្រតិបត្តិការ និងសម្រេចបាននូវគោលដៅបានកំណត់ ។ ដោយហេតុនេះ សវនកម្មនឹងផ្តោតទៅលើកម្មវត្ថុសំខាន់ៗ ដូចជា: អត្ថិភាព ភាពគ្រប់គ្រាន់ សង្គតិភាព សុពលភាព ភាពជាប់លាប់នៃការប្រើប្រាស់នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ការគោរពអនុលោមភាពតាមផែនការ នីតិវិធី និងបទដ្ឋានច្បាប់ ពិសេសវិន័យថវិកា ១១ "ខ" ភាពត្រឹមត្រូវនិងទាន់ពេលនៃការកត់ត្រាចម្លងការ គណនេយ្យភាព និងប្រសិទ្ធភាពប្រតិបត្តិការ ពិសេសការប្រមូលចំណូល និងការចំណាយ ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងនិងរក្សាសុវត្ថិភាពនៃទ្រព្យសម្បត្តិ ភាពសន្សំសំចៃក្នុងការប្រើប្រាស់ធនធានសាធារណៈ កិច្ចសហប្រតិបត្តិការរវាងអង្គភាព គុណភាពនៃការពង្រឹងសមត្ថភាព និងការគ្រប់គ្រងមុខងារមន្ត្រីរាជការ រួមទាំងគោលជំហររបស់ថ្នាក់ដឹកនាំសវនដ្ឋាន (អង្គភាពរងសវនកម្ម) ផងដែរ។

ដូច្នេះ ដើម្បីឲ្យការងារសវនកម្មតាមកម្មវត្ថុខាងលើសម្រេចបានល្អ ថ្នាក់ដឹកនាំសវនដ្ឋាន និងមជ្ឈដ្ឋានពាក់ព័ន្ធ ត្រូវផ្តល់ការយកចិត្តទុកដាក់ និងកិច្ចសហការជិតស្និទ្ធជូនដល់សវនករ ដោយផ្តល់នូវសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យ និងចូលដល់ផ្នែកផ្សេងៗនៃអង្គភាព ពិសេសឯកសារពាក់ព័ន្ធដូចជា: លិខិតបទដ្ឋានច្បាប់ របាយការណ៍ បញ្ជិកា ផែនការ ស្ថិតិទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ និងមន្ត្រីរាជការ ព្រមទាំងឯកសារចាំបាច់ដទៃ ដោយអាចធ្វើតេស្តលើភាពត្រឹមត្រូវដល់ទីកន្លែង ។ ទន្ទឹមនឹងនេះ សវនករត្រូវបំពេញការងារសវនកម្មដោយឯករាជ្យ មិនលំអៀង ស្របតាមស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនករផ្ទៃក្នុង ដើម្បីផ្តល់នូវអនុសាសន៍កែលម្អសំដៅបន្ថែមតម្លៃ ជួយឱ្យអង្គភាពសំរេចគោលដៅដែលបានកំណត់ ។ ការតាមដានទៅលើការកែលម្អតាមអនុសាសន៍ នឹងត្រូវធ្វើក្នុងរយៈពេល ៦ ខែក្រោយសវនកម្មបានបញ្ចប់ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវចុះធ្វើសវនកម្មទៅតាម: ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៣ ករណីចាំបាច់លើមូលដ្ឋានបណ្តឹង សំណូមពររបស់អង្គភាពក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយជូននិងមិនជូនដំណឹងជាមុន ។

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តមប្រតិភូ លោកជំទាវ ឯកឧត្តម លោកស្រី លោកជ្រាប និងចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ ២០១៣ នេះ ឱ្យបានសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

*ចំលងជូន:*
- អាជ្ញាធរសវនកម្មជាតិ
- សាលារាជធានីភ្នំពេញ និងសាលាខេត្ត "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ